ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

EAC

**អាជ្ញាធរអគ្គិសនីកម្ពុជា**

លេខ៥៣៤.លណ.១៥អអក

ភ្នំពេញ, ថ្ងៃទី ០៥ ខែ ឧសភា ឆ្នាំ២០១៥

# សេចក្តីជូនដំណឹងរបស់អាជ្ញាធរអគ្គិសនីកម្ពុជា ស្តីពីការពិគ្រោះយោបល់លើការកែសម្រួលបញ្ចុះអត្រាថ្លៃលក់អគ្គិសនីនៅក្នុងតំបន់ធ្វើសេវាកម្មផ្គត់ផ្គង់អគ្គិសនីរបស់អ្នកកាន់អាជ្ញាប័ណ្ណចំនួន ១២២ តំបន់ នៅខេត្តកំពង់ឆ្នាំង ខេត្តពោធិ៍សាត់ ខេត្តបាត់ដំបង ខេត្តបន្ទាយមានជ័យ ខេត្តកំពង់ចាម និងមួយចំនួននៅខេត្តកណ្តាល ខេត្តព្រៃវែង ខេត្តតាកែវ និងខេត្តត្បូងឃ្មុំ

អាជ្ញាធរអគ្គិសនីកម្ពុជា សូមជម្រាបជូនសាធារណជនដែលជាអ្នកប្រើប្រាស់អគ្គិសនីនៅក្នុងតំបន់ធ្វើសេវាកម្មផ្គត់ផ្គង់អគ្គិសនីរបស់អ្នកកាន់អាជ្ញាប័ណ្ណចំនួន ១២២ តំបន់ នៅខេត្តកំពង់ឆ្នាំង ខេត្តពោធិ៍សាត់ ខេត្តបាត់ដំបង ខេត្តបន្ទាយមានជ័យ ខេត្តកំពង់ចាម និងមួយចំនួននៅខេត្តកណ្តាល ខេត្តព្រៃវែង ខេត្តតាកែវ និងខេត្តត្បូងឃ្មុំ ដែលមានបញ្ជីឈ្មោះភ្ជាប់មកជាមួយ មេត្តាជ្រាបថា កន្លងមក អាជ្ញាធរអគ្គិសនីកម្ពុជា បានបញ្ចុះថ្លៃលក់អគ្គិសនីឲ្យអ្នកកាន់អាជ្ញាប័ណ្ណនៅតំបន់ខាងលើ មកស្មើនឹង ១,១០០រៀលក្នុង១គីឡូវ៉ាត់ម៉ោង ដើម្បីសម្រួលដល់ជីវភាពរស់នៅរបស់ប្រជាពលរដ្ឋអ្នកប្រើប្រាស់ផង និងទុកលទ្ធភាពឲ្យអ្នកធ្វើសេវាកម្មអាចរក្សាបានដំណើរការផ្គត់ផ្គង់អគ្គិសនីផង ។ យោងតាមផែនការយុទ្ធសាស្ត្របន្ថយអត្រា និងគម្លាតថ្លៃលក់អគ្គិសនីនៅព្រះរាជាណាចក្រកម្ពុជាពីឆ្នាំ២០១៥ ដល់ឆ្នាំ ២០២០ និងយោងតាមទំហំទីផ្សារ និងបរិមាណថាមពលលក់កើនឡើងជាងមុន រួចហេដ្ឋារចនាសម្ព័ន្ធចែកចាយក៏បានអភិវឌ្ឍន៍ជិតពេញដែនអាជ្ញាប័ណ្ណដែរ អាជ្ញាធរអគ្គិសនីកម្ពុជាបានពិនិត្យគណនាវិភាគថ្លៃដើមអគ្គិសនីសម្រាប់ការធ្វើសេវាកម្មរបស់អ្នកកាន់អាជ្ញាប័ណ្ណដែលកំពុងលក់ថ្លៃស្មើនឹង ១,១០០រៀលក្នុង១គីឡូវ៉ាត់ម៉ោង ឃើញថា ថ្លៃដើមអគ្គិសនីចែកចាយសរុបបានថយចុះបានមួយចំនួនហើយ ដូច្នេះអាជ្ញាធរអគ្គិសនីកម្ពុជាគ្រោងបញ្ចុះអត្រាថ្លៃលក់របស់អ្នកកាន់អាជ្ញាប័ណ្ណទាំងនោះមកអត្រាថ្លៃលក់ថ្មី ដូចខាងក្រោម ៖

| **ប្រភេទប្រើប្រាស់** | **អត្រាថ្លៃលក់អគ្គិសនី** |
|---|---|
| អតិថិជនទូទៅ ទិញលើតង់ស្យុងទាប | 1,050 រៀល / kWh |
| អតិថិជនឧស្សាហកម្ម ពាណិជ្ជកម្ម ទិញអគ្គិសនីលើតង់ស្យុងមធ្យម | 0.1725 $US / kWh |
| អតិថិជនឧស្សាហកម្ម ពាណិជ្ជកម្ម ទិញអគ្គិសនីលើតង់ស្យុងទាប និងជាអ្នកវិនិយោគតម្លើងត្រង់ស្វូ នាឡិកាស្ទង់ LV និងឌីស្យុងទ័រួម LV * | 0.180 $US / kWh |

*អតិថិជនឧស្សាហកម្ម ពាណិជ្ជកម្ម ជាអ្នកវិនិយោគតម្លើងត្រង់ស្វូរ អានុភាពចាប់ពី 50kVA ឡើងទៅ។

ដើម្បីឲ្យមានតម្លាភាព អាជ្ញាធរអគ្គិសនីកម្ពុជាស្នើសុំឲ្យក្រសួង-ស្ថាប័នរបស់រាជរដ្ឋាភិបាល និង អ្នកប្រើប្រាស់ទាំងអស់ដែលពាក់ព័ន្ធនឹងថ្លៃនេះ សូមមេត្តាពិនិត្យ ផ្តល់មតិលើឯកសារគណនាវាយតម្លៃ លើការបញ្ចុះអត្រាថ្លៃលក់អគ្គិសនីនៅក្នុងតំបន់ធ្វើសេវាកម្មរបស់អ្នកកាន់អាជ្ញាប័ណ្ណទាំង ១២២ តំបន់ ចាប់ពីថ្ងៃជូនដំណឹងនេះ **រហូតដល់ថ្ងៃទី២៥ ខែឧសភា ឆ្នាំ២០១៥ ។ ក្រោយថ្ងៃទី២៥ ខែឧសភា ឆ្នាំ២០១៥** គម្រោងបញ្ចុះថ្លៃលក់អគ្គិសនីនេះ នឹងត្រូវចាត់ទុកថាបានឆ្លងកាត់ការពិគ្រោះយោបល់រួច ហើយអាជ្ញាធរ អគ្គិសនីកម្ពុជានឹងអាចធ្វើការពិនិត្យ និងអនុម័តកែសម្រួលបញ្ជីថ្លៃលក់នេះ ទៅតាមការកំណត់របស់ច្បាប់ ស្តីពីអគ្គិសនីនៃព្រះរាជាណាចក្រកម្ពុជា ។ ដោយសារគម្រោងកែសម្រួលថ្លៃលក់ខាងលើ គឺជាគម្រោងកែ សម្រួលថ្លៃលក់ជាក្រុមសម្រាប់អ្នកកាន់អាជ្ញាប័ណ្ណចំនួន១២២តំបន់ ដូច្នេះ អាជ្ញាធរអគ្គិសនីកម្ពុជាសូមផ្តល់ នូវឯកសារគណនាថ្លៃដើម-ថ្លៃលក់អគ្គិសនីរបស់អ្នកកាន់អាជ្ញាប័ណ្ណចំនួន ១០ ជាគំរូ ។

អាជ្ញាធរអគ្គិសនីកម្ពុជាសូមបញ្ជាក់ថា ការផ្តល់យោបល់លើឯកសារគណនា វាយតម្លៃ ដែលភ្ជាប់មក ជាមួយ សូមមានមូលដ្ឋានសំអាងគ្រប់គ្រាន់ ដើម្បីឲ្យអាជ្ញាធរអគ្គិសនីកម្ពុជាអាចពិនិត្យបាន ទៅតាមការកំណត់ របស់ច្បាប់ស្តីពីអគ្គិសនីនៃព្រះរាជាណាចក្រកម្ពុជា និងអនុក្រឹត្យលេខ៥៤.អនក្រ.បក ចុះថ្ងៃទី០៨ ខែមេសា ឆ្នាំ២០០៥ និងត្រូវរក្សាបាននូវតុល្យភាពយុត្តិធម៌ រវាងផលប្រយោជន៍របស់អ្នកប្រើប្រាស់ផងអគ្គិសនីផង និង អ្នកផ្គត់ផ្គង់អគ្គិសនីផង ។

ឯកសារកែសម្រួលអត្រាថ្លៃលក់អគ្គិសនីឲ្យអ្នកកាន់អាជ្ញាប័ណ្ណជាគំរូ ច្បាប់ស្តីពីអគ្គិសនីនៃព្រះរាជា-ចក្រកម្ពុជា និងអនុក្រឹត្យលេខ ៥៤.អនក្រ.បក ចុះថ្ងៃទី០៨ ខែមេសា ឆ្នាំ២០០៥មានតម្កល់ទុកនៅ .......................... .................................................................................................................. សម្រាប់ សាធារណជនទាំងអស់ ដែលមានចំណាប់អារម្មណ៍ពិនិត្យដោយសេរី នៅគ្រប់ពេលម៉ោងធ្វើការ ។

អាស្រ័យហេតុនេះ សូមសាធារណជនទាំងអស់ ដែលមានចំណាប់អារម្មណ៍ចង់ពិនិត្យ និងផ្តល់ យោបល់ មេត្តាជ្រាបជាពត៌មាន ។

**អាជ្ញាធរអគ្គិសនីកម្ពុជា**

**ប្រធាន**

**បណ្ឌិត.ទី នរិន្ទ**